# មេរៀនទី ១៣៧: សាឡូម៉ូនងាកបែរពីព្រះ

## ១ពង្សាវតារក្សត្រ ១១:១-១៣

| |
|---|
| **គោលបំណង៖** ព្រះទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នា។ |

| |
|---|
| **ខគម្ពីរចងចាំ៖ ចោទិយកថា ៦:៥** *"ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង។"* |

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ប្រាជ្ញាដែលយើងអាចរកបាននៅក្នុងព្រះគម្ពីរមិនគ្រាន់តែដឹងការពិតអំពីព្រះយេស៊ូវទេ-វាគឺជាការរស់នៅដោយមិត្តភាពជាមួយ និងការគោរពចំពោះព្រះគ្រីស្ទ។ ប្រាជ្ញាបង្កើតឱ្យមានការផ្លាស់ប្តូរ មិនមែនគ្រាន់តែជាពត៌មានប៉ុណ្ណោះទេ។ សូមអាន **២ របាក្សត្រ ៧:១៤**។ ជាយូរមកហើយមុនពេលដែលចិត្តរបស់សាឡូម៉ូនវង្វេង ហើយដោយសារសេចក្តីល្បួងដាច់ឆ្ងាយពីព្រះ នោះព្រះបានដឹកនាំផ្លូវគាត់និងរាស្ត្ររបស់គាត់ដើម្បីស្តារចំណងមិត្តភាពរបស់ពួកគេជាមួយនឹងព្រះ។ យើងអាចធ្វើតាមផ្លូវដែលព្រះបានបង្ហាញឲ្យត្រឡប់ទៅរកព្រះវិញ ពេលយើងមិនស្តាប់បង្គាប់របស់ទ្រង់។ សូមចំណាយពេលមួយនាទីដើម្បីឆ្លុះបញ្ចាំងហើយពិចារណាពីតម្រូវការរបស់អ្នកដើម្បីសារភាពអំពើបាបចំពោះព្រះ។

| |
|---|
| **ចំរៀង៖** ១. ក្បាល ស្មា ជង្គង់ ចុងជើងសរសើរព្រះអង្គ ២. សរសើរព្រះយេស៊ូវ ៣. ចូរប្រយ័ត្ននឹងភ្នែកតូចអ្នក |

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «តាតាសុំដូង ឬតាតាសុំភ្លើង»



**សម្ភារៈដែលត្រូវការ៖** គុមួយ កៅអីមួយ

១. ជ្រើសកុមារម្នាក់ដើរតួជាតា ហើយកុមារម្នាក់ទៀតដើរតួជាអ្នកសុំដូង

២.ឲ្យកុមារដែលនៅសល់ចែកជាពីរក្រុម។ ក្រុមមួយដើរតួជាឃ្មុំ ក្រុមមួយដើរតួជាដូង។

៣. ក្រុមដូងត្រូវអង្គុយជាជួរតោងចង្កេះគ្នា កុមារដំបូងរបស់ក្រុមដូងត្រូវតោងភ្ជាប់ជាមួយជើងគុ ហើយសមាជិកផ្សេងទៀតតោងគ្នាបន្ត។ ក្រុមឃ្មុំអាចតោងនៅលើដូងណាមួយក៏បាន។

៤. ពេលអ្នកសុំទៅដល់គេត្រូវនិយាយថា "តាៗសុំដូងមួយ" តាតបថា"ស្រលាញ់មួយណាបេះមួយហ្នឹងចុះ" អ្នកសុំតបថា "អរគុណតា"។

៥. អ្នកសុំក៏ដើរទៅបេះដូងដែលគេចង់បាន។ ប្រសិនបើគេបេះចំដូងដែលមានឃ្មុំនោះឃ្មុំនឹងទិចគេ។ ហើយគេនឹងចាញ់ល្បែងនេះ។

៦. ប្រសិនបើអ្នកសុំមិនរើសចំដូងដែលមានឃ្មុំទេនោះគេនឹងឈ្នះ ហើយដើរតួជាឃ្មុំវិញម្តង។

៧. អ្នកដែលជាដូងត្រូវបានគេសុំនោះត្រូវធ្វើជាអ្នក ទៅសុំដូងគាវិញម្តង។
៨.មិនយូរមិនឆាប់កុមារដែលជាអ្នកសុំ នឹងត្រូវរើសយកដូងដែលមានឃ្មុំនោះហើយគេនឹងចាញ់ល្បែងនេះ។
៩.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ប្រសិនបើយើងចង់សុំអ្វីពីព្រះ នោះទ្រង់នឹងប្រទានដល់យើង ប្រសិនបើរបស់នោះមិនធ្វើឲ្យយើងឈឺចាប់។ ព្រះសមនឹងទទួលបានការថ្វាយបង្គំដ៏ពេញលេញពីយើងដោយសារទ្រង់ស្រលាញ់យើង ហើយទ្រង់នឹងប្រទាននូវអ្វីដែលយើងត្រូវការ។

## ៤. ការណែនាំមេរៀន

នៅពេលដែលប្អូនប្រាប់ឪពុកម្តាយរបស់ប្អូនថាប្អូនស្រលាញ់គាត់ តើប្អូនស្រលាញ់ពួកគាត់ដោយអស់ពីចិត្តឬមួយយ៉ាងណា? តើប្អូនមានអារម្មណ៍ដូចម្តេច នៅពេលដែលម្តាយរបស់ប្អូនប្រាប់ប្អូនថា គាត់ស្រលាញ់ប្អូនមិនអស់ពីចិត្តរបស់គាត់នោះ? តើការនោះធ្វើឲ្យប្អូនសប្បាយឬក៏ទុក្ខសោក? ព្រះចង់ឲ្យយើងស្រលាញ់ទ្រង់ឲ្យអស់ពីចិត្តរបស់យើង។ ពីព្រោះទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នា។ នេះគឺមានន័យថាទ្រង់សមនឹងទទួលបាននូវសេចក្តីស្រលាញ់ និងការទុកចិត្តពីយើងរាល់គ្នាគ្រប់ពេលនិងជារៀងរាល់ថ្ងៃ។ ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ដែលមិនបានថ្វាយបង្គំព្រះឲ្យអស់ពីចិត្តរបស់គាត់នោះទេ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាឡូម៉ូនជាស្តេចរបស់សាសន៍អ៊ីស្រាអែល។ ស្តេចសាឡូម៉ូនគឺស្រឡាញ់និងបម្រើព្រះ។ គាត់បានផ្តល់សេចក្តីស្រឡាញ់ដល់ព្រះគ្រប់ពេលវេលា។ គាត់ស្រឡាញ់ព្រះពេលគាត់នៅជាមួយគ្រួសាររបស់គាត់។ គាត់ស្រឡាញ់ព្រះពេលគាត់នៅជាមួយមិត្តរបស់គាត់។ គាត់ស្រឡាញ់ព្រះហើយស្តាប់បង្គាប់ព្រះគ្រប់ពេល ដែលគាត់ព្យាយាមដោះស្រាយបញ្ហាកើតឡើងក្នុងប្រទេសអ៊ីស្រាអែល។ គាត់បានថ្វាយបង្គំព្រះនៅឯព្រះវិហារ។ ដួងចិត្តទាំងអស់របស់សាឡូម៉ូនគឺសម្រាប់ព្រះ។

ប៉ុន្តែបន្ទាប់មកសាឡូម៉ូនមិនស្តាប់បង្គាប់ព្រះ។ គាត់បានរៀបការជាមួយស្ត្រីខ្លះដែលមិនស្រឡាញ់ព្រះ។ ស្ត្រីទាំងនេះគោរពបូជារូបព្រះ ហើយពួកគេមិនចង់ឲ្យសាឡូម៉ូនថ្វាយបង្គំព្រះឡើយ។ ដូច្នេះជាជាងស្រឡាញ់ព្រះគ្រប់ពេលនោះ សាឡូម៉ូនបានងាកបែរចេញពីព្រះបន្តិចម្តងៗ ហើយដួងចិត្តដែលស្រលាញ់ព្រះក៏នៅសល់តែបន្តិចប៉ុណ្ណោះ។ ដួងចិត្តដែលនៅសេសសល់គាត់បានប្រគល់ទៅឲ្យស្រីៗទាំងនោះអស់ហើយ។

បន្ទាប់មក គាត់ចាប់ផ្តើមថ្វាយបង្គំរូបព្រះជាមួយនឹងស្ត្រីដែលគាត់បានរៀបការជាមួយនោះ! សាឡូម៉ូនលែងប្រគល់ដួងចិត្តទាំងអស់ថ្វាយដល់ព្រះទៀតហើយ។ ហើយព្រះមិនចង់បានគ្រាន់តែជាផ្នែកមួយនៃចិត្តយើងទេ។ ព្រះបានមានបន្ទូលប្រាប់សាឡូម៉ូនថាទ្រង់ខឹងណាស់ ហើយទ្រង់នឹងយករាជបល្ល័ង្កចេញពីកូនរបស់សាឡូម៉ូន ដូច្នេះគ្រួសាររបស់សាឡូម៉ូននឹងលែងធ្វើជាស្តេចលើដែនដីអ៊ីស្រាអែលទៀតហើយ។

ព្រះសមនឹងទទួលបានដួងចិត្តរបស់យើងទាំងស្រុង។ ទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នាពីព្រោះទ្រង់អស្ចារ្យណាស់។ មានតែព្រះប៉ុណ្ណោះដែលអស្ចារ្យសមនឹងទទួលបានសេចក្តីស្រឡាញ់របស់យើងគ្រប់ពេលវេលា។ ទ្រង់ស្រឡាញ់យើង ហើយយកចិត្តទុកដាក់ចំពោះយើង ហើយទ្រង់បានបង្កើតពិភពលោកទាំងមូលសម្រាប់យើង។ យើងគួរស្រឡាញ់ព្រះ ហើយដើរតាមមាគ៌ារបស់ព្រះអង្គ ពេលយើងនៅផ្ទះនៅ

ជាមួយមិត្តភ័ក្តិ នៅព្រះវិហារ និងគ្រប់ទីកន្លែងដែលយើងទៅ។ យើងគួរតែស្រឡាញ់ទ្រង់គ្រប់ពេលវេលា។ យើងគួរតែផ្តល់ឲ្យព្រះអង្គនូវដួងចិត្តទាំងអស់របស់យើង។

**៦. សំនួរពិភាក្សា**

១. ហេតុអ្វីបានជាសាឡូម៉ូនងាកបែរចេញពីព្រះ? *គាត់បានរៀបការជាមួយស្ត្រីខ្លះដែលមិនជឿព្រះ*

២. តើព្រះបានមានបន្ទូលដូចម្តេចទៅកាន់សាឡូម៉ូន?

*ទ្រង់ខឹងណាស់ ហើយទ្រង់នឹងយករាជបល្ល័ង ចេញពីកូនរបស់សាឡូម៉ូន*

៣. តើយើងត្រូវធ្វើដូចម្តេច ដើម្បីបង្ហាញពីសេចក្តីស្រលាញ់របស់យើងដែលមានចំពោះព្រះ?

*យើងគួរតែផ្តល់ឲ្យព្រះអង្គនូវដួងចិត្តទាំងអស់របស់យើងទៅព្រះ ដោយការអធិស្ឋាន ការថ្វាយបង្គំ និងការដែលចិត្តល្អចំពោះមិត្តភក្តិ ។ល។*

៤. តើយើងគួរប្រគល់ដួងចិត្តរបស់យើងប៉ុនណាសម្រាប់ព្រះ? *ដួងចិត្តទាំងមូលរបស់យើង*

**៧. ល្បែងកំសាន្ត «ព្រះទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នា»**



១. ឲ្យកុមារទាំងអស់ឈរនៅចំកណ្តាលថ្នាក់រៀន។

២. គ្រូនឹងអានប្រយោគ ហើយនៅពេលដែលសិស្សលឺ "ចន្លោះ ដែលទំនេរ" គេត្រូវរត់ទៅរកចម្លើយ ដែលត្រឹមត្រូវនោះ។ ប្រសិនបើ កុមារគិតថា ចម្លើយទី១ ត្រឹមត្រូវពួកគេត្រូវរត់ទៅខាងស្តាំ ហើយពួកគេត្រូវរត់ទៅខាងឆ្វេងបើគិតថា ចម្លើយទី ២ត្រឹមត្រូវ។

ក. សាឡូម៉ូនងាកបែរចេញពីព្រះដោយសារ....... (**ប្រពន្ធគាត់**/ទ្រព្យសម្បត្តិ)

ខ. ទ្រង់នឹងយក .......(ទ្រព្យសម្បត្តិ/**រាជបល្ល័ង្គ**)ចេញពីកូនរបស់សាឡូម៉ូន

គ. មានតែ......(**ព្រះ**/ជីតា) ប៉ុណ្ណោះដែលអស្ចារ្យសមនឹងទទួលបានសេចក្តីស្រឡាញ់របស់យើងគ្រប់ពេលវេលា។

ឃ. ទ្រង់ស្រឡាញ់យើងហើយយកចិត្តទុកដាក់ចំពោះយើង ហើយទ្រង់បានបង្កើត.............. (**ពិភពលោក**/ផែនដីខ្លះ) ទាំងមូលសម្រាប់យើង។

ង. យើងគួរស្រឡាញ់ព្រះហើយដើរតាមមាគ៌ារបស់ព្រះអង្គ ពេលយើងនៅផ្ទះ នៅជាមួយមិត្តភ័ក្តិ នៅព្រះវិហារ និង ......(**គ្រប់ទីកន្លែង**/កន្លែងមួយចំនួន )ដែលយើងទៅ។

ច. យើងគួរស្រលាញ់ព្រះ .......(**គ្រប់ពេល**/ពេលខ្លះ)

ឆ. យើងគួរតែស្រឡាញ់ទ្រង់គ្រប់ពេលវេលា។ យើងគួរតែផ្តល់ឲ្យព្រះអង្គនូវ ...............(**ដួងចិត្តទាំងអស់**/លុយទាំងអស់)របស់យើង។

៣. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងគួរតែស្រឡាញ់ទ្រង់គ្រប់ពេលវេលា។ យើងគួរតែផ្តល់ឲ្យព្រះអង្គនូវដួងចិត្តទាំងអស់របស់យើង ពីព្រោះទ្រង់ស្រលាញ់យើងហើយចង់ឲ្យយើងនូវអ្វី ដែលល្អដល់យើង។

**៨. ខគម្ពីរចងចាំ** ចោទិយកថា ៦:៥

**៩. ហត្ថកម្ម** «អស់ពីដួងចិត្តខ្ញុំ»




**សម្ភារៈដែលត្រូវការៈ** សូមបោះពុម្ពរូបបេះដូងនៅខាងក្រោម កូលស៊ និងកន្ត្រៃ

១. សូមបោះពុម្ពក្រដាសរូបបេះដូងសម្រាប់កុមារគ្រប់ៗគ្នា

២. ឲ្យកុមារកាត់រូបបេះដូងចេញមកហើយតុបតែងវា

៣. បត់រូបបេះដូងមួយចំហៀងសងខាងចូលគ្នា ដើម្បីធ្វើជាគម្របបេះដូងពេញ

៤. នៅចំកណ្ដាលរូបបេះដូងសូមឲ្យកុមារសរសេរថា “ ខ្ញុំស្រលាញ់ព្រះអស់ពីដួងចិត្តខ្ញុំ!”

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

